ព្រះរាជាណាចក្រកម្ពុជា
ROYAUME DU CAMBODGE

ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION ROI

អាជ្ញាធរអប្សរា
APSARA
N° ២០៤/១៤.ឥ.អ.ជ/វ

# សេចក្តីជូនដំណឹង
# ស្តីពី
# ការដាក់ពាក្យស្នើសុំសេវាផ្សេងៗ របស់អគ្គនាយកដ្ឋានអាជ្ញាធរអប្សរា

អាជ្ញាធរអប្សរា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាម្ចាស់សណ្ឋាគារ ប្រធានក្រុមហ៊ុនទេសចរណ៍ និងអ្នកប្រើប្រាស់សេវាទាំងអស់មេត្តាជ្រាបថា: អាជ្ញាធរអប្សរាបានបង្កើត និងដាក់ឱ្យដំណើរការមជ្ឈមណ្ឌលសេវាកម្មនៃអាជ្ញាធរអប្សរា (ម.ស.អ) សម្រាប់ផ្តល់ជូនអ្នកប្រើប្រាស់សេវាទាំងអស់ ចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៨ តាមយន្តការច្រកចេញ-ចូលតែមួយ ។ ទន្ទឹមនឹងនេះ កន្លងមកការរៀបចំពិធីសម្តែងសិល្បៈ និងទទួលទានអាហារ នៅតាមប្រាសាទនានាក្នុងតំបន់រមណីយដ្ឋានអង្គរ មានសណ្ឋាគារ និងក្រុមហ៊ុនទេសចរណ៍មួយចំនួនតូចដែលជាអ្នករៀបចំពិធី ពុំបានជូនដំណឹងអំពីចំនួនភ្ញៀវទេសចរលើស តាមខ្លឹមសារកំណត់ក្នុងលិខិតអនុញ្ញាតរបស់អាជ្ញាធរអប្សរាទេ ។ ដើម្បីជៀសវាងបញ្ហាខាងលើនេះ ម្ចាស់សណ្ឋាគារ ទីភ្នាក់ងារទេសចរណ៍ និងអ្នកប្រើប្រាស់សេវាទាំងអស់ត្រូវគោរពតាមការកំណត់ដូចខាងក្រោម ៖

១-ត្រូវជូនដំណឹងអំពីចំនួនភ្ញៀវលើសមកអាជ្ញាធរអប្សរា០៣ថ្ងៃ (នៃថ្ងៃធ្វើការដោយមិនរាប់បញ្ចូលថ្ងៃឈប់សម្រាក និងថ្ងៃបុណ្យជាតិ) មុនថ្ងៃរៀបចំពិធី ដោយគិតចាប់ពីថ្ងៃបោះលេខចូល ម.ស.អ ក្នុងម៉ោងធ្វើការ ។

ឧទាហរណ៍ -បើសិនថ្ងៃស្នើសុំរៀបចំពិធីនៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៤ ត្រូវជូនដំណឹងយ៉ាងយូរត្រឹមថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៤ ។

-បើសិនថ្ងៃស្នើសុំរៀបចំពិធីនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៤ ត្រូវជូនដំណឹងយ៉ាងយូរត្រឹមថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៤ (ព្រោះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៤ ជាថ្ងៃបុណ្យជាតិ និងថ្ងៃសៅរ៍ ទី២១, ថ្ងៃអាទិត្យ ទី២២ ខែមិថុនា ឆ្នាំ២០១៤ ជាថ្ងៃឈប់សម្រាកមិនត្រូវបានរាប់បញ្ចូលទេ)

២-ក្នុងករណីក្រុមហ៊ុនបានបង់ថ្លៃសេវារួចរាល់ ក្រុមហ៊ុនពុំអាចដកថវិកាដែលបានបង់នោះពីអាជ្ញាធរអប្សរាបានទេ ទោះជាករណីចំនួនភ្ញៀវស្នើសុំបានថយចុះក៏ដោយ លើកលែងតែ ក្នុងករណីក្រុមហ៊ុនស្នើសុំលុបពិធី ទើបអាចដកថវិកាបានតាមរយៈពេលកំណត់ដូចមានចែងក្នុងកិច្ចសន្យា ។

អាជ្ញាធរជាតិដើម្បីការពារតំបន់ និងរៀបចំតំបន់អង្គរ
AUTORITE POUR LA PROTECTION DU SITE ET L'AMENAGEMENT DE LA REGION D' ANGKOR
Website : http://www.autoriteapsara.org
E-mail : apsara-admin@camnet.com.kh

PHNOM PENH :
#41, Russi Federal Bvd., Meatapheap, 7Makara
Téléphone : (855-23) 215 771
Télécopie : (855-23) 215 776

SIEM REAP :
Bang Korng, Ampil, Town Siem Reap, Province
Téléphone : (855-63) 765 577, 766 676
Télécopie : (855-63) 765 576

៣-ដោយឡែកចំពោះប្រជាពលរដ្ឋដែលរស់នៅតំបន់កោះកែរ តំបន់បេងមាលា និងតំបន់ផ្សេងទៀត ស្ថិតក្រោមការគ្រប់គ្រងដោយនាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរ នៃអគ្គនាយកដ្ឋានអាជ្ញាធរអប្សរា ដែលមានបំណងសុំច្បាប់សាងសង់ផ្ទះ សូមអញ្ជើញទៅទំនាក់ទំនងតំណាងនាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរ ដែលប្រចាំការនៅទីនោះស្រាប់ និងទទួលចម្លើយតាមរយៈតំណាង ដែលនៅប្រចាំការទីនោះ លើកលែងតែករណីវិនិយោគ ។

ន័យដូចបានជម្រាបជូនខាងលើនេះ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាម្ចាស់សណ្ឋាគារ និងប្រធានក្រុមហ៊ុនទេសចរណ៍ និងអ្នកប្រើប្រាស់ទាំងអស់មេត្តាជ្រាប និងចូលរួមសហការអនុវត្តតាមការគួរ ។

សៀមរាប ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០១៥

**អគ្គនាយក**

សុខ លក្ខិណា

**ចម្លងជូនៈ**

-ក្រសួងទេសចរណ៍
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរអប្សរា

" ដើម្បីគោរពជូនជ្រាប"

-សាលាខេត្តសៀមរាប
-សាលាខេត្តព្រះវិហារ
-គ្រប់នាយកដ្ឋានអាជ្ញាធរអប្សរា
-មន្ទីរទេសចរណ៍ខេត្តសៀមរាប
-អង្គភាពនគរបាលការពារបេតិកភណ្ឌ ប្រចាំខេត្តសៀមរាប
-សមាគមសណ្ឋាគារកម្ពុជា
-សមាគមទីភ្នាក់ងារទេសចរណ៍
-សមាគមមគ្គុទ្ទេសក៍ទេសចរណ៍
-សមាគមចុងភៅកម្ពុជា

" ដើម្បីជូនជ្រាប និងសហការអនុវត្ត"

-ឯកសារ-កាលប្បវត្តិ